00824126

E172/24/5/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 07 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២

ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ: ចម្លើយតបទៅនឹងសំណើសុំលើកទីពីររបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងឯកសារដែលប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David CHANDLER (ឯកសារ E172/24/5)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់មេធាវីការពារជនជាប់ចោទ អៀង សារី ដើម្បីដាក់ឯកសារចំនួន ០៥ នៅចំពោះមុខអង្គជំនុំជម្រះ និងស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារទាំងនេះក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David CHANDLER ដោយអនុលោមតាមវិធាន ៨៧(៤)។

២. ដូចដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានលើកឡើង ឯកសារទាំងអស់ដែលស្ថិតក្នុងប្រភេទ (គ), (ឃ) និង (ង) នៅក្នុងសំណើ E172/24/5 របស់ខ្លួន ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជី

ឯកសារដែលភាគីផ្សេងៗបានស្នើឡើងសម្រាប់អង្គហេតុដែលត្រូវធ្វើសវនាការនៅដំណាក់កាលដំបូង[1] ។ អង្គជំនុំជម្រះសូមរំឭកឡើងវិញនូវសេចក្ដីណែនាំមុនរបស់ខ្លួនដែលថា "ឯកសារណាមួយដែលភាគីមានបំណងប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ហើយឯកសារនោះពុំទាន់ទទួលបានចំណាត់ថ្នាក់ជាឯកសារ E3 [...] ឬមិនត្រូវបានលើកឡើងនៅក្នុងបញ្ជីឯកសារណាមួយ ដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" (ឯកសារ E199) ។ ដោយហេតុថាឯកសារដែលស្ថិតក្នុងប្រភេទ (គ) ដល់ (ង) ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងកាលពីខែ កក្កដា ឆ្នាំ ២០១១ រួចហើយនោះ ពុំមានភាពចាំបាច់ដែលត្រូវអនុវត្តវិធាន ៨៧(៤) ពាក់ព័ន្ធនឹងឯកសារទាំងនេះទៀតឡើយ ។ ឯកសារទាំងនេះអាចត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ ប្រសិនបើឯកសារទាំងនេះបានបំពេញលក្ខខណ្ឌនៃភស្តុតាងដូចមានចែងក្នុងវិធាន ៨៧(៣)។

៣. ឯកសារដែលស្ថិតក្នុងប្រភេទ (ក) និង (ខ) នៅក្នុងឯកសារ E172/24/5 ពុំត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសារដែលភាគីណាមួយផ្សេងទៀតបានស្នើឡើយ។ ប៉ុន្តែឯកសារទាំងនេះគ្រាន់តែជាសៀវភៅដែលបោះពុម្ពខុសពីគ្នា ដែលត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឯកសាររបស់ភាគីផ្សេងៗ[2]។ អង្គជំនុំ-

---

[1] ឯកសារ D288/4.59.1 ត្រូវបានដាក់បញ្ចូលជាឯកសារលេខ 51 នៅក្នុងបញ្ជី E109/4.11 របស់សហព្រះរាជអាជ្ញា; ឯកសារ D108/50/1.74 ត្រូវបានដាក់បញ្ចូលជាឯកសារលេខ 169 នៅក្នុងឯកសារ E109/4.19; ហើយឯកសារ D222/1.16 គឺជាឯកសារលេខ 243 នៅក្នុងឯកសារ E109/4.19។

[2] ឯកសារ (ក) ("ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (A History of Cambodia)", បោះពុម្ពលើកទី ៤) ត្រូវជាឯកសារលេខ 173 នៅក្នុងបញ្ជី E109/4.19 របស់សហព្រះរាជអាជ្ញា, ("ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (A History of Cambodia)", បោះពុម្ពលើកទី ៣), ដែលស្ថិតនៅក្នុងសំណុំរឿង ក្នុងលក្ខណៈជាឯកសារ D366/7.1.69។ ឯកសារ (ខ) ("ប៉ុល ពត៖ បងទីមួយ (Brother Number One: A Political Biography of Pol Pot)", បោះពុម្ពលើកទី ១) ត្រូវជាឯកសារលេខ 171 នៅក្នុងឯកសារ E109/4.19 ("ប៉ុល ពត៖ បងទីមួយ (Brother Number One: A Political Biography of Pol Pot)", បោះពុម្ពកំណែសម្រួល), ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយមានលេខឯកសារ E3/17។ មេធាវីការពារជនជាប់ចោទ អៀង សារី ពុំបានយកចិត្តទុកដាក់ផ្ដល់ព័ត៌មាននេះនៅក្នុងសំណើរបស់ខ្លួនឡើយ។ អង្គជំនុំជម្រះសូមរំឭកភាគីជាថ្មីថា នៅពេលភាគីស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ភាគីគួរគប្បីផ្ដល់ព័ត៌មានឱ្យបានពេញលេញអំពីបញ្ជីឯកសារទាំងនេះមកអង្គជំនុំជម្រះ (ប្រសិនបើមាន) ដែលក្នុងបញ្ជីទាំងនេះ ឯកសារត្រូវបានកំណត់អត្តសញ្ញាណ៖ ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៩៣-៩៤។

ជម្រះសូមរំឭកថាអង្គជំនុំជម្រះធ្លាប់បានអនុញ្ញាតឲ្យភាគីដាក់ឯកសារថ្មីទៅក្នុងសំណុំរឿងដោយយឺតយ៉ាវ ដោយសំអាងថាឯកសារថ្មីនោះពាក់ព័ន្ធជិតស្និទ្ធជាមួយឯកសារដែលត្រូវបានកំណត់អត្ត-សញ្ញាណត្រឹមត្រូវនៅក្នុងបញ្ជីរបស់ភាគី ហើយអនុញ្ញាតឲ្យសៀវភៅបោះពុម្ពខុសៗគ្នាទាំងនេះទទួលបានការវាយតម្លៃជាមួយគ្នា ដើម្បីផលប្រយោជន៍នៃយុត្តិធម៌។ ហេតុដូច្នេះ ឯកសារដែលស្ថិតក្នុងប្រភេទ (ក) និង (ខ) អាចត្រូវបានចាត់ទុកថាដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងយកទៅប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David CHANDLER ដរាបណាឯកសារទាំងនេះបំពេញលក្ខខណ្ឌតម្រូវដូចសព្វមួយដងដែលមានចែងក្នុងវិធាន ៨៧(៣)។

៤. នេះជាចម្លើយជាផ្លូវការរបស់អង្គជំនុំជម្រះ តបទៅនឹងសំណើ E172/24/5 ។